# វត្តទេពប្រណម្យ

វត្តទេពប្រណម្យស្ថិតនៅជាប់ផ្លូវជាតិលេខ៥ នៅក្នុងភូមិទេពប្រណម្យឃុំវិហារហ្លួង ស្រុកពញាឮ ខេត្តកណ្តាល ចម្ងាយប្រមាណ៤៥គីឡូម៉ែត្រខាងជើងនៃរាជធានីភ្នំពេញ ។

ចំពោះឈ្មោះ ទេពប្រណម្យនេះ យើងឃើញមានទីតាំងបុរាណសំខាន់ពីរផ្សេងគ្នាគឺមួយនៅព្រះវិហារទេពប្រណម្យ ក្នុងក្រុងអង្គរធំ និងមួយទៀតគឺទីតាំងនៃវត្តទេពប្រណម្យឧដុង្គនេះឯង។ ទេពប្រណម្យ គឺជារូបទេពស្រីលុតជង្គង់ និងលើកដៃសំពះ ដែលក្នុងរូបថតរបស់ លោកស្រី Madelene Giteau ក្នុងឆ្នាំ ១៩៦៣ បានបង្ហាញអំពីរូបទេពប្រណម្យនេះដែលនៅជុំវិញព្រះវិហារចាស់វត្តទេពម្រណម្យ ហើយនេះប្រហែលជាដើមចមនៃការហៅវត្តទេពប្រណម្យ និងឈ្មោះនៃវត្តនេះក៏មាននិយាយក្នុងរឿងព្រេងនៃតាដុង យាយជ័យដែរ។

អ្នកស្រាវជ្រាវដំបូងៗដែលបានសិក្សាលើទីវត្តទេពប្រណម្យនេះ គឺមានដូចជា អ្នកស្រី Madeleine Giteau និងនិស្សិតបុរាណវិទ្យាឆ្នាំ១៩៦៩ ដែលដឹកនាំដោយសាស្រ្តាចារ្យបារាំងមកសិក្សាលម្អិតពីទីតាំងវត្តនេះ ។ គួរបញ្ជាក់ដែរថា អត្ថបទស្រាវជ្រាវទាំងនោះ គឺសុទ្ធសឹងតែជាភាសាបារាំង។[១]

ទីតាំងវត្តទេពប្រណម្យនេះ គឺជាទីតាំងមួយសំខាន់ក្នុងប្រវត្តិសាស្រ្តខ្មែរ ព្រោះមានតឹងតាងតាំងពីសម័យបុរេប្រវត្តិ អង្គរ និងរហូតដល់បច្ចុប្បន្ន ដោយឃើញមានឧបករណ៍ថ្មព្រះវិហារចាស់ដំបូងគេ គឺយកថ្មប្រាសាទតម្រៀបជាខឿនព្រះវិហារ[២] ឃើញមានរូបទេពស្រីធ្វើពីថ្មភក់សតវត្សទី១០[៣] បំណែករូបមដិមាថ្មភក់ និងវត្ថុសិល្បៈជាច្រើនទៀត(រូបលេខ១-៣)។

ចំពោះកាលបរិច្ឆេទនៃការកសាងវត្តទេពប្រណម្យ យើងពុំបានដឹងនោះទេ ប៉ុន្តែប្រហែលជាកសាងពាក់កណ្តាលសតវត្សទី១៦ ឬ ដើមស.វ.ទី១៧ ដែលបានបង្ហាញតាម

[១] ខ្ញុំនឹងដាក់ចំណងជើងនៃអត្ថបទស្រាវជ្រាវទាំងនោះនៅក្នុងឯកសារយោង។

[២] ដូចសំណង់ព្រះវិហារសម័យកណ្តាលក្នុងតំបន់អង្គរ ដែលយកថ្មប្រាសាទតម្រៀបជាខឿនព្រះវិហារ ។

[៣] GITEAU 1963:37 ; និស្សិតបុរាណវិទ្យា 1969:31.

អត្ថបទដោយ៖ អេង តុលា

រយៈរឿងព្រេងតាដុង យាយដ័យ[៤] អ្នកស្រុកស្រុកឧត្តុង្គជឿថា រឿងព្រេងនេះទាក់ទងនឹងការកសាងវត្តទេពប្រណម្យនេះ ។

ព្រះវិហារនៅក្នុងវត្តដែលយើងឃើញសព្វថ្ងៃនេះ គឺកសាងនៅឆ្នាំ ២០០០ (រូបលេខ៤) ដែលកសាងបន្ទាប់ព្រះវិហារចាស់ឆ្នាំ១៩៦៩[៥] ប៉ុន្តែព្រះវិហារចាស់នោះបានខូចខាតក្នុងសម័យប៉ុលពត ព្រះវិហារឆ្នាំ១៩៦៩នោះ គឺកសាងនៅលើព្រះវិហារចាស់មួយទៀតដែលយកថ្មប្រាសាទតម្រៀបខឿនព្រះវិហារ។ ចំពោះព្រះវិហារនេះកសាងនៅឆ្នាំ១៩០៩[៦] ហើយឃើញមានរូបទេពប្រណម្យនៅជុំវិញនៃព្រះវិហារនោះ ប្រហែលជាកសាងនៅសតវត្សទី១៧។[៧]

អ្វីដែលសំខាន់នោះគឺ ការរកឃើញវត្ថុសិល្បៈបុរាណជាច្រើននៅឆ្នាំ ១៩៦៩ ប្រមាណជាង ៤២០ វត្ថុ[៨] ក្នុងនោះ មានដូចជាឧបករណ៍បុរេប្រវត្តិ ព្រះពុទ្ធរូបអំពីមាស ប្រាក់ សំរិទ្ធ ថ្មភក់ កងដៃ ចង្រ្កង់ កណ្ដឹង តុំកំបោរ អំពីសំរិទ្ធ វត្ថុអំពីឈើ កុលាលភាជន៍សម័យអង្គរ និងប្រភេទ Porcelain ជាច្រើន។ យើងពុំបានដឹងអំពីទីតាំងដើមនៃវត្ថុទាំងនោះទេ ប៉ុន្តែការរកឃើញវត្ថុទាំងនោះ គឺនៅទីតាំងពីរកន្លែងផ្សេងៗ មួយរកឃើញនៅពេលគេរុះរើចេតិយចំណាស់មួយនៅក្បែរព្រះវិហារចាស់ឆ្នាំ១៩០៩ ដែលនៅខាងមុខនៃក្លោងទ្វារខាងកើត និងការរកឃើញមួយទៀត គឺនៅពេលដែលគេរុះរើព្រះវិហារចាស់ឆ្នាំ១៩០៩ ដែលក្នុងនោះភាគច្រើន គឺជាការរកឃើញរូបបដិមាអំពីសំរិទ្ធជាច្រើន និងវត្ថុអំពីសំរិទ្ធផ្សេងៗទៀត។ បដិមាដែលបានរកឃើញទាំងអស់នោះ ស្ទើតែទាំងអស់ គឺជាបំណែកដងខ្លួន ព្រះកេស និងដៃ។ នៅឆ្នាំ១៩៧០ អ្នកស្រី Madeleine Giteau បានមកថតរូប និងសិក្សាអំពីរូបបដិមាដែលមានសភាពល្អៗ និងនៅឆ្នាំ ១៩៧១ លោកស្រីបោះពុម្ពអត្ថបទអំពីរូបបដិមាអំពីសំរិទ្ធចំនួន៤[៩] ដែលមកពីវត្តទេពប្រណម្យ ។ នៅឆ្នាំ១៩៦៩ វត្ថុទាំងអស់នោះគឺ រក្សាទុកនៅក្នុងកុដិរបស់

---

[៤] និស្សិតបុរាណវិទ្យា 1969:31

[៥] GITEAU 1971:149; GUERET DEMANGEON 2015:82

[៦] និស្សិតបុរាណវិទ្យា 1969:34

[៧] GITEAU 1975:201

[៨] អេង តុលា ២០២០ :១០

[៩] GITEAU 1971:149

AMS អរិយធម៌ខ្មែរ

ព្រះចៅអធិការវត្ត និងបានបញ្ជូនមករក្សាទុកនៅសារមន្ទីរជាតិ មុនពេលសម័យសង្គ្រាមស៊ីវិល ។

លោកស្រី M. Giteau បានលើកឡើងថាការកប់វត្ថុក្នុងន័យសាសនាទាំងនេះ គឺធ្វើឡើងនៅដើមសតវត្សទី១៩ ។ រីឯទំនៀមនៃការប្រមូលវត្ថុផ្សេងៗយកទៅកប់នេះ គឺយើងឃើញមានតាំងពីសម័យបុរាណមកម៉្លេះ ។

រូបបដិមាទាំងបួនដែលលោកស្រី M.Giteau បានសិក្សា នោះគួរឱ្យចាប់អារម្មណ៍ព្រោះលោកស្រីបង្ហាញថា រូបទី១ជារូបព្រះពុទ្ធឈរ ក្នុងរចនាបទលប់បុរី សតវត្សទី១៣ (រូបលេខ៥) បដិមាទី២ស្ថិតក្នុងរចនាបទ Early Ayutthaya ដែលលោកស្រីលើកឡើងថាកសាងដោយជាងខ្មែរ[១០](រូបលេខ៦) រូបទី៣ជារូបព្រះពុទ្ធ មានខ្លួនក្នុងរចនាបទបាយ័ន្តប៉ុន្តែព្រះកេសរចនាបទអយុធ្យា[១១] (រូបលេខ៧) និងរូបទី៤ជារូបព្រះពុទ្ធឈរ ក្នុងទម្រង់អភ័យមុទ្រលោកស្រីបានលើកឡើងថាទម្រង់មុខគឺក្នុងរចនាបទបាយ័ន្ត និងកសាងក្នុងសតវត្សទី១៦ (រូបលេខ៨)។ នៅក្នុងអត្ថបទរបស់លោក Martin Polkinghorne ក៏បានបង្ហាញអំពីរូបបដិមាអយុធ្យា ដែលមាននៅក្នុងប្រទេសកម្ពុជា អំឡុងពេលអយុធ្យាគ្រប់គ្រងអង្គរ ដែលហៅថារចនាបទ Early Ayutthaya។[១២]

បើយើងធ្វើការប្រៀបធៀបរវាងបំណែកបដិមា (ព្រះកេស) សំរិទ្ធដែលបានរកឃើញក្នុងវត្តទេពប្រណម្យ និង សិល្បៈអយុធ្យា (Early Ayutthaya) និង សុខោទ័យ យើងឃើញថាការតុបតែង ការឆ្លាក់ក្បួងសក់, ទម្រង់មុខ ចិញ្ចើម បបូរមាត់ គឺដូចគ្នាស្ទើរតែទាំងស្រុង។

ដូចបានបង្ហាញខាងលើនេះ ទីតាំងវត្តទេពប្រណម្យ គឺជាទីតាំងប្រវត្តិសាស្ត្រយ៉ាងសំខាន់មួយ ជាពិសេសវត្ថុសិល្បៈដែលបានរកឃើញ គឺជាផ្នែកមួយក្នុងការស្រាវជ្រាវពីសិល្បៈសម័យកណ្តាលឲ្យបានស៊ីជម្រៅ និង ទំនាក់ទំនងរវាងសិល្បៈខ្មែរ និងថៃលើបដិមា។

---

[១០] GITEAU 1971:150

[១១] សូមអាន GITEAU 1971:149,150,151

[១២] សូមអាន Evidence for the 15th century Ayutthayan occupation of Angkor .



រូបលេខ១៖ រូបថតចាស់នៃព្រះវិហារ និងរូបគំនូរឆ្នាំ១៩០៩

(ប្រភព៖ GITEAU ១៩៦៣)



រូបលេខ២២៖ រូបទេពប្រណម្យអំពីថ្មភក់ខាងមុខព្រះវិហារឆ្នាំ១៩០៩ (ប្រភព៖ GITEAU ១៩៦៣)



រូបលេខ២៣៖ រូបទេពស្រី
(ប្រភព៖ GITEAU ១៩៦៣)



រូបលេខ២៤៖ ព្រះវិហារបច្ចុប្បន្ន
ថតឆ្នាំ ២០២០

អត្ថបទដោយ៖ អេង តុលា



រូបលេខ៥ និង ៦ ៖ ព្រះពុទ្ធរូប

(ប្រភព៖ GITEAU ១៩៧១)

KHMER CIVILIZATION



— 4 —



— 5 —

រូបលេខ៧ ៖ ព្រះពុទ្ធរូប

ប្រភព៖ GITEAU ១៩៧១



— 6 —



— 7 —

រូបលេខ៨ ៖ ព្រះពុទ្ធរូប
ប្រភព៖ GITEAU ១៩៧១



ព្រះកេសដែលរកឃើញ
នៅវត្តទេពប្រណម្យ

រូបលេខ៩ ៖ ព្រះពុទ្ធរូបក្នុងរចនាបទ Early Ayutthayan ឃើញមាននៅក្នុងស្រុកខ្មែរ (ប្រភព៖ Martin Polkinghorne)

អត្ថបទដោយ៖ អេង តុលា

# ឯកសារយោង

Étudiants de la Faculté Royale d’Archéologie de Phnom Penh

1968 « Nos activités depuis 1965 », Bulletin des étudiants de la Faculté d’Archéologie, 1, p. 38-43.

1969 « Le monastère bouddhique de Tep Pranam à Oudong, I. Le vihāra, II. Le monastère de Tep Pranam, III. Légendes et croyances relatives à la pagode et à ses génies, IV. Les dévots laïcs de la paroisse de Vat Tep Pranam »

GITEAU, Madeleine

1963 « Sanctuaires bouddhiques du Cambodge. Tep Pranam », *Le Cambodge d’aujourd’hui*, 58, p. 35-37

1971Notes sur quelques pièces en bronze récemment découvertes à Vatt Deb Pranamy D’oudong (Utun) », *Arts Asiatiques,* 24, p. 149-159.

1975 « *Iconographie du Cambodge post-angkorien* », Paris, EFEO, Publications l’EFEO.

GUERET DEMANGEON, Danielle

2015 *Le décor peint des monastères bouddhiques du Cambodge fin du XIXe siècle – Troisième quart du XXe siècle*, thèse de doctorat, Paris, Université Paris IV-Sorbonne,3 volumes,1947, p. 82.

POLKINGHORNE, Martin, Christophe POTTIER et Christian FISCHER

2018 « Evidence for the 15th century Ayutthayan occupation of Angkor », in The Siam Society under Royal Patronage, *The Renaissance Princess Lectures In Honour of Her Royal Highness Princess Maha Chakri Sirindhorn on Her Fifth Cycle Anniversary*, Bangkok, The Siam Society under Royal Patronage, p. 99-132.

ENG Tola

2020 « L’ancienne collection archéologique du monastère bouddhique de Vat Tep Pranam à Oudong : inventaire et étude » Master 1, INALCO-URBA.

AMS
KHMER CIVILIZATION